(3)

D00003

កាលពីថ្ងៃទី ២២ និង ២៣ ខែតុលា ឆ្នាំ ១៩៨១ នៅសាលចតុមុខរដ្ឋធានីភ្នំពេញ តុលាការប្រជាជនបដិវត្តរដ្ឋធានីភ្នំពេញ បាន បើកសវនាការ ជំនុំជំរះកាត់ទោសជនក្បត់ បដិវត្ត ៦នាក់ពីបទធ្វើវិទ្ធ្វេសកម្មអុកឡុកសម្លាប់ កម្មាភិបាលកងទ័ព និងប្រជាជននិងការសុំ គ្រលំបិទបាំងលាក់បំពួន អោយខ្មាំងស្នាក់អា ស្រ័យព្រមទាំង ជួយឧបត្ថម្ភស្បៀងអាហារ ដោយចេតនា ។

ជនក្បត់ទាំង នោះសុទ្ធសឹងតែជាអតីត នាយទាហានរងរបស់ពួក ទាហានបាក់ទ័ព ប៉ុល ពតដែលបានប្រមែប្រមូលបក្សពួកខិត ខំធ្វើចលនាវិទ្ធ្វេសកម្ម អុកឡុកប្រឆាំងបដិវត្ត នៅក្រោម ខ្សែញាក់និងឧបត្ថម្ភយ៉ាង ពេញទំហឹងពីសំណាក់ពួក ចក្រពត្តិល្មោភ សង្គ្រាមអាមេរិកនិងអនុត្តរភាព និយមចិនប៉េ កាំងពួករាជ្រត្រូវក្រសួងមានសមត្ថកិច្ចរួមសហ ការយ៉ាងជិតស្និទ្ធជាមួយរដ្ឋអំណាចនិងប្រជា ជនកម្ពុជា គ្រប់ជាន់ថ្នាក់តាមដានយ៉ាងប្រកិត ហើយចាប់ខ្លួនបានជាបន្តបន្ទាប់ ។

ក្នុងសវនាការតុលាការ ដោយមាន ភស្តុតាងត្រឹមត្រូវ ជនក្បត់ទាំង ៦ រូបបាន ឆ្លើយសារភាព ហើយសំដែងនូវវិប្បដិសារីចំ ពោះទោសកំហុស របស់ខ្លួន ដែលបានអនុវត្ត កន្លងមក ដោយធ្វើសំណូមពរចំពោះអង្គការ បដិវត្តសុំឲ្យបន្ធូរបន្ថយទោសតាមគោលនយោបាយមនុស្សធម៌ ដល់ខ្លួន ដើម្បីនឹងខិតខំរៀនសូត្រកសាង ខ្លួនឡើងវិញ ព្រមទាំងធ្វើការអំពាវនាវចំ- ពោះបក្សពួកខ្លួន ដែលល្ងិតល្ងង់ជឿលើសំដី ឃោសនារបស់ខ្មាំង អោយឆាប់វិលត្រឡប់ ចូលមកសារភាពចំពោះមុខរដ្ឋអំណាចបដិវត្ត ដើម្បីរួមចំណែកកសាង និងការពារប្រទេស ជាតិវិញ ដោយអះអាងថា រណសិរ្សកសាង មាតុភូមិកម្ពុជាពុំចាប់ទោសអ្វីទាំងអស់ចំពោះ ការយល់ភ័ន្តច្រឡំចាញ់បោករបស់ខ្មាំង ។

ក្រោយពីពិភាក្សាវែកញែក យ៉ាងល្អិត ល្អន់ តុលាការបានសម្រេចកាត់ទោស :

១ កែវ - បៃ ហៅ កែវ - វ៉ន ឃុំខ្លួន មួយជីវិត

២ — ប៉ែន ឈិត ហៅ ប៉ែន - លន ឃុំខ្លួន ២០ ឆ្នាំ

៣ — សុក សំ ហៅ សុក - សារ ឃុំខ្លួន ១៤ ឆ្នាំ

៤ ហ៊ុន-ញ៉េន ហៅ ហ៊ុន - ញ៉ ឃុំខ្លួន ១២ ឆ្នាំ

៥ — កែ - រៀន ហៅ កែ - ផេង ឃុំខ្លួន ១១ ឆ្នាំ

៦ — នារី គង់ - ស៊ុម ព្យួរទោស ២ ឆ្នាំ

(3)



ជនក្បត់ឈ្មោះ : កែប - បៃ , សុក - សំ , ប៉ែន - ឈិត , កែ - រៀន , ហ៊ុន - ញ៉េន និង គង់ - ស៊ុម នៅពីមុខឈើរាងរង្វង់ក្រចកសេះ ថតដោយ ស.ម អ៊ិត ប៊ុនថៃ

## ឧក្រិដ្ឋកម្មរបស់ ប៉ុល ពត អៀង សារី ខៀវ សំផន



ជើងឯកផាកខ្ទេងមួយកាប់សម្លាប់មនុស្ស

ឃុំជើងឯក ក្នុងស្រុកដង្កោរ ខេត្តកណ្ដាល ប៉ែកនិរតីក្រុងភ្នំពេញ ចម្ងាយប្រហែល ១២ គ.ម ជាទីកន្លែង ដែលពួក ប៉ុល ពត យកមនុស្សទៅសម្លាប់យ៉ាងរង្គាល មានចំនួន ១២៩ រណ្ដៅ ហើយបច្ចុប្បន្នជីកបាន ៨៥ រណ្ដៅ រកឃើញ និង យកបាននូវលលាដ៍ក្បាលចំនួន ៨,៩៨២ ។

និងពួកប្រល័យពូជសាសន៍ ប៉ុល-ពត អៀង សារី ខៀវសំផន ចារវារផាច់ថ្លៃរបស់ពួករាតទីនិយមបើកនែបន្សល់ទុកមក ។

យើងទាំងអស់គ្នា ក៏ដឹងហើយថា : បច្ចុប្បន្ននេះ ប្រាក់ចំណាយទាំងឡាយក្នុងមួយឆ្នាំៗ នៅលើការរត់ប្រណាំងផ្នែកសព្វាវុធ បានឡើងទៅដល់ ៥៥០ កោដិដុល្លា។ សព្វថ្ងៃនេះទៀត ឃ្លាំងផ្ទុកអាវុធបរិមាណូនៅលើសកលលោក បានកើនឡើងៗ ជាលំដាប់ ។ សេចក្តីសម្រេចចិត្តរបស់ប្រធានាធិបតីរីហ្គិន មេដឹកនាំនយោបាយល្មោភសង្គ្រាមអាមេរិក ដើម្បីផលិតកម្មគ្រាប់បែកណឺត្រុង ដែលមានកម្លាំងបំផ្លាញមនុស្សជាតិយ៉ាងឆាប់រហ័សនោះ ជាការមាក់ងាយយ៉ាងខ្លាំង ចំពោះមនុស្សលោក។ ឃាត់ឃាំងនូវវិនាសកម្ម ដោយសារសង្គ្រាមនុយក្លេអ៊ែរនេះ គឺជាភារកិច្ចជាបន្ទាន់ ដែលមនុស្សជាតិយើងទាំងមូល ត្រូវតស៊ូ ដើម្បីទទួលនូវជ័យជំនះ ជាស្ថាពរ គឺសន្តិភាព សុភមង្គល លើទ្វីបទាំងមូល ។ ក្នុងទសវត្ស កន្លងទៅ សកម្មភាពទាំងឡាយ របស់សហភាពសូវៀត ព្រមទាំងគ្រោះថ្នាក់បំផុត ។ ថ្មី ៗ នេះគេបានផលិតកម្មអាវុធណឺត្រុង បំណងនឹងដណ្តើមមកវិញនូវឧត្តមភាពផ្នែកយោធា ។ ការរត់ប្រណាំងផ្នែកសព្វាវុធ នេះជាការគំរាមកំហែង មនុស្សជាតិយើង ដោយសង្គ្រាមបរិមាណូ ប្រកបដោយទំហំវិនាសកម្មពុំដែលជួបប្រទះ ។ នយោបាយឈ្លានពានបង្កសង្គ្រាមរបស់ចក្រពត្តិអាមេរិក អំពើជិះជាន់សង្កត់សង្កិន ដ៏ព្រៃផ្សៃរបស់ពួកអាណានិគមចាស់ថ្មី និងពួកសក្តិភូមិ បានរុញច្រានសកលលោកយើង ចូលក្នុងវិបត្តិស្មុគ្រស្មាញធំ ៗ។ ទូរលេខខាងក្រោមនេះ ជាភស្តុតាងស្រាប់ :

- មនុស្សដែលហូបចុក មិនបានគ្រប់គ្រាន់មានចំនួន ៥៧០ លាននាក់
- អ្នកគ្មានថ្នាំពេទ្យ ឬ គ្រូពេទ្យព្យាបាល ១.៥០០ លាននាក់
- ចាស់មិនចេះអក្សរ ៨០០ លាន នាក់
- អ្នកគ្មានផ្ទះនៅត្រឹមត្រូវ ១.០៣០ លាននាក់ ។
- ក្មេងគ្មានសាលារៀន ២៥០ លាននាក់
- អ្នកគ្មានការធ្វើ ១.១០៣ លាននាក់

បរិមាណូនៅអ៊ីរ៉ាក់ ។ អំពើឈ្លានពាននិងការទម្លាក់គ្រាប់បែករបស់ពួកអាហ្វ្រិក ខាងត្បូងនៅអង់ហ្គោឡា ក៏មានការចូលរួមរបស់ចក្រពត្តិអាមេរិកដែរ ។ អាមេរិកដំណើរការសមយុទ្ធរួមជាមួយបក្សសម្ព័ន្ធ អាត្លង់ទិក « អូតង់ » ជាមួយថៃ ... ទាំងនេះសុទ្ធសឹងជាភស្តុតាង ដែលបញ្ជាក់ច្បាស់ថា ចក្រពត្តិអាមេរិក ជាអ្នកបង្កស្ថានភាពការណ៍តានតឹង និងគំរាមកំហែងដោយសង្គ្រាមនៅលើសកលលោក ។

ប្រជាជនកម្ពុជាក៏ដូចជាប្រជាជនស្នេហាសន្តិភាពនៅលើសកលលោកដែរបានថ្កោលទោសយ៉ាងដាច់អហង្កាចំពោះ នយោបាយបង្កសង្គ្រាមរបស់ចក្រពត្តិអាមេរិក ។ យើងប្រឆាំងដាច់ខាតចំពោះ សេចក្តីសំរេចចិត្តរបស់រដ្ឋការរីហ្គិន ក្នុងការផលិតអាវុធណឺត្រុងហើយគាំទ្រយ៉ាងក្លៀវក្លា ចំពោះសំណើសន្តិភាពរបស់សហភាពសូវៀត ។ ប្រជាជនទាំងមូលត្រូវការ សន្តិភាពនិងចង់រស់នៅក្នុងសន្តិភាពពិតប្រាកដ ។ ដកពិសោធន៍ក្នុងប្រវត្តិសាស្ត្រកន្លងមកយើងបានដឹងច្បាស់ថា បើចង់បានសន្តិភាពនិង រក្សាសន្តិភាពគឺជិតស្និទ្ធជាមួយប្រជាជនវៀតណាម ឡាវ និងប្រទេសសង្គមនិយមជាបងប្អូន ព្រមទាំងប្រទេសស្នេហាសន្តិភាព នៅលើសកលលោក ដើម្បីវាយកំទេចគ្រប់អនុភាពប្រតិកិរិយាបង្កសង្គ្រាមអោយ បរាជ័យក្នុងបំណងដណ្តើមយកសន្តិភាព សេរីភាពយូរអង្វែងជូនមាតុប្រទេស ជាទីស្នេហារបស់យើងហើយកសាងមិនឈប់ឈរ ជីវភាពរស់នៅរបស់ប្រជាជនយើងគ្រប់ៗ ប្រាណប្រកបដោយសុភមង្គលនិងសេរីភាព ។ នោះជាទង្វើប្រកបដោយលទ្ធផលដ៏ ប្រសើរបំផុត ដើម្បីរួមចំណែកដ៏ធំធេងក្នុងការ តស៊ូដើម្បីសន្តិភាពជូនមនុស្សជាតិទាំងមូល ក្នុងសកលលោក ។

ប្រាក់ សុខុន